# ឱ! មហាភ្នំដងរែក

## អនុស្សាវរីយ៍ដ៏មហាខ្លោចផ្សាក្នុងរបបសម័យខ្មែរក្រហម



## ព្រះតេជគុណ អគ្គធីរោ លី ឋាន់

ព្រះចៅអធិការ វត្ត ពន្លឺពុទ្ធចក្រ
ទីក្រុងឡូវែល, រដ្ឋម៉ាស្សាឈូសែត, សហរដ្ឋអាមេរិក
គ.ស. ១៩៨២ - ព.ស. ២៥២៥

រៀបចំចងក្រងបោះពុម្ពដោយ

**យឿន សំខាន់**

មេសា ២០០៩

# ឱ! មហាភ្នំឯវរ៉េត

## អនុស្សាវរីយ៍ដ៏មហាខ្លោចផ្សាក្នុងរបបសម័យខ្មែរក្រហម

*នមោនមស្សការលើកហត្ថាឱនសិរសី*
*គ្រានេះនឹងសម្ដែងថ្លែងដំណាលពីព្រឹត្តិការណ៍*
*បង្គំរតនត្រៃដាក់តម្កល់លើសិរសា*
*ប្រវត្តិសាស្រ្តដ៏ខ្លោចផ្សារាស្រ្តកម្ពុជាត្រូវរងទុក្ខ ។*

*ដប់ប្រាំពីរមេសាមួយពាន់ប្រាំបួនរយចិតប្រាំ*
*ខ្មែរក្រហមវាសម្លាប់ស្លាប់រង្គាលគ្រប់ភូមិស្រុក*
*ប្រជារាស្រ្តត្រូវរងកម្មជិតបួនឆ្នាំក្នុងនរក*
*ខ្លះសម្លាប់ទាំងទារកអស់ទាំងពូជគ្មានប្រណី ។*

*វារឹបអូសយកអស់ទ្រព្យរបស់ទាំងប៉ុន្មាន*
*ទីក្រុងស្ងាត់ជ្រងំផ្ទះធំៗ រុះហិនហៃ*
*ស្លាបព្រានិងឆ្នាំងចានកាំបិតពូថៅកញ្ជើល្អី*
*ជម្លៀសរាស្រ្តទៅនៅព្រៃគាស់រានដីគ្រប់មណ្ឌល ។*

*វត្តអារាមយកធ្វើគុកឃុំអ្នកស្រុកធ្វើទោសពៃរ៍*
*ពុទ្ធរូបទាំងធំតូចវាវាយខ្ទេចអស់គ្មានសល់*
*គម្ពីរអដ្ឋបាលីចោលដាសដីតាមជើងថ្កល់*
*មន្រ្តីសង្ឃគ្រប់មណ្ឌលស្លាប់គ្មានសល់ដោយប្រល័យ។*

*ពង្រាត់អស់កុមារព្រាត់ប្រាសគ្នាពីម៉ែឪ*
*អ្នកខ្លះប្រាសច្រើនខួបមិនដែលជួបកូនប្រុសស្រី*
*បំបែកនាំយកទៅទុកឲ្យនៅស្ថានដទៃ*
*ទោះឈឺឬស្លាប់ក្តីក៏ឥតបីបានដឹងដែរ ។*

*ធ្វើការជាទម្ងន់ស៊ូអត់ធន់ព្រោះខ្លាចក្ស័យ*
*ស៊ីបបររាវកខ្វក់សោជាងជ្រូកអន់លើសឆ្កែ*
*វាវាយធាក់មនុស្សស្រីដែលមានផ្ទៃជិតគ្រប់ខែ*
*ម្ហូបអាហារច្រើនបន្លែស្ងោរតែផ្សិនិងត្រកួន ។*

*ដាច់បបរបួនប្រាំថ្ងៃវាឲ្យស៊ីតែកន្ទក់*
*គ្មានកម្លាំងទៅធ្វើការចោរមោហាវារុកគួន*
*ហេវពេកដេកមិនលក់មុខស្លាំងស្លក់ស្គមទាំងខ្លួន*
*ខំត្រដររលុះស្លាប់ខ្លួនប្រពន្ធកូននៅកំព្រា ។*

*ស្រីក្រមុំខ្ទូចរូបឆោមកាយទ្រុឌទ្រោមដូចជាយាយ*
*ជង្គង់ធំជាងភ្លៅក្បាលនោះកូវធំជាងស្មា*
*ប្រុសកម្លោះផងទាំងឡាយខ្លួនប្រែក្លាយដូចជាតា*
*ជ្រុះអស់ទាំងកេសាឈឺគ្រាំគ្រាជាទម្ងន់ ។*

*មុខហើមភ្នែកលឿងស្លេកគ្មានថ្នាំពេទ្យព្យាបាលរោគ*
*ដាច់ពោះស្លាប់ជិតអស់គ្មានស្រណោះប្រជាជន*
*ស្លាប់អស់ច្រើនគរគោករោគរាតត្បាតគ្រប់តំបន់*
*ហេវហត់ស្លាប់ទាន់ហន់កប់មិនទាន់រាល់ខែថ្ងៃ ។*

*ខ្លះខំគេចភៀសប្រាណវាចាប់បានវាយសម្លាប់*
*មួយរយរត់រួចមួយស្លាប់រង្គួយពាសពេញព្រៃ*
*ខ្លះត្រូវមីនផ្ទុះងាប់ខ្លះបាញ់ស្លាប់ជិតដែនថៃ*
*ពួកវាឃាមរាល់ថ្ងៃចាំប្រល័យគ្រប់ទិសទី ។*

វាស្ត្រត្រូវអន្តរធានស្លាប់វាល់លានដោយដៃទមិឡ
ស្លាប់ដោយធ្វើការធ្ងន់ខ្លះស្លាប់ដោយគ្មានបាយស៊ី
ចាប់ចងកាប់ផ្តាច់ផ្តិលឆ្អឹងដេរដាសពេញធរណី
អត់ម្ហូបឃ្លានពេញទីស៊ីកណ្តុរជាអាហារ ។

លុះឆ្នាំចិតប្រាំបួនយួនចូលវាយកំចាត់ទមិឡ
ឯកឧត្តមហេងសំរិនឡើងគ្រប់គ្រងរដ្ឋកម្ពុជា
ខែមួយថ្ងៃប្រាំពិលទមិឡបោលចូលព្រៃព្រឹក្សា
វាស្ត្ររាងចាលក៏នាំគ្នាភៀសអាត្មាចោលស្រុកស្រែ ។

ចូលដល់ព្រំដែនថៃចោរចង្រៃប្លន់យកអស់
ចោរសៀមវាវាយតប់ជ្រមុញទ្រូបលើភ្លីស្រែ[1]
មាសពេជ្រទ្រព្យរបស់គ្មានសល់សោះទាំងចិនខ្មែរ
ឆែកខ្លួនគ្មានសល់ទេឆេររហូតទ្វារតូចធំ ។

រួចផុតពីចោរប្លន់ចូលតំបន់ភូមិណាងចាន
បញ្ជូនជនភៀសប្រាណរាប់រយឡានដោយបង្ខំ
មិនអាចស្នាក់យូរបានសៀមសាមាន្យវាធាក់ច្រំ
ដឹកទៅដាក់នាជួរភ្នំព្រំដែនខែត្រព្រះវិហារ ។

លុះព្រឹកឡើងដេញឲ្យចុះបាញ់បង្រុះស្លាប់ច្រើនក្រៃ
ភិតភ័យខ្លាំងក្រៃលែងរត់ប្រដែងពារលើគ្នា
ក្មេងចាស់ទាំងប្រុសស្រីនិងកូនខ្ចីស្លាប់ត្រៀបត្រា
ដណ្តើមចុះពីបុព្វតារអន្ទះសាព្រោះខ្លាចក្បៀយ ។

ផ្លូវចុះភ្នំចោតចង្អៀតខំប្រជ្រៀតប្រពូនគ្នា
ទម្លាក់សំពាយចុះពួកប្រុសៗ លោតចុះខ្មី
ប្រតោងឫសរុក្ខាមែកព្រឹក្សាលតា[2]ព្រៃ
ចាំទទួលយកកូនខ្ចីតពីដៃនៃមាតា ។

ចុះពីព្រឹកលុះរសៀលទើបដល់ក្នុងជ្រលងភ្នំ
ពួកខ្លះរកកាច់ឧសផ្ទុះគ្រាប់ស្លាប់ច្រើនមហិមា
សងខាងព្រៃជិតជុំភ្នំមួយគូទន្ទឹមគ្នា
ខ្លះស្វែងរកគង្គាជាន់ត្រូវមីនផ្ទុះស្លាប់ទៅ ។

ជនភៀសខ្លួនច្រើនម៉ឺននាក់ធ្លាក់នៅក្នុងភាពអាសន្ន
នឹងងាកថយក្រោយវិញសៀមស្ទាក់បាញ់មិនឲ្យទៅ
តក់ស្លុតភ័យស្លោស្លន់នឹកគុណព្រះ-គុណម៉ែឪ
នឹងទៅមុខឥតមានផ្លូវក្រាស់ដោយស្មៅនិងស្បូវភ្លាំង ។

ចុះទឹកជួបក្រពើឡើងទៅលើប្រទះខ្លា
គ្រានោះពួកចាមថ្វាហ៊ានពុះពារយ៉ាងក្លាខ្លាំង
ចូលព្រៃទាក់បន្លាឡើងរុក្ខាវាក់នឹងស្រាំង
បើកផ្លូវជាអាទិ៍តាំងមីនផ្ទុះក្ខាំងស្លាប់ត្រៀបត្រា ។

“ **ឱ! មហាភ្នំដងរែក** វែងអនេកធំស្កឹមស្កៃ
សូរស័ព្ទរៃកណ្តឹងយំទ្រហឹងឆ្លើយឆ្លងគ្នា
ដើមស្រឡៅខ្ពស់ត្រៃឈៃត្របែកព្រៃជ្រៃជន្លា
ស្រណោះដល់ជនកម្ពុជាចរលើលាកំសត់ក្រៃ ។”

---

[1] បានហូដោះយកខ្សែក្រវាត់មាសពីចង្កេះកែវអោយទៅសៀម ហើយចោរសៀមវាដាល់មួយដៃផ្កាប់មុខទៅនឹងភ្លឺស្រែ ព្រោះវាខឹងដោយក្រអោយខ្សែក្រវាត់ទៅវា គឺថា បើវាមិនកំហែងយើងមិនអោយវា។

[2] លតាជាតិ ជាតិវល្លិ៍គ្រប់ប្រភេទតែងដុះវារឡើងដើមឈើ។

ដើររុកក្នុងព្រៃជ្រៅពារលើស្មៅស្បូវស្បាតក្រាស់ គ្រាប់មីនផ្ទុះច្រើនណាស់ត្រូវក្មេងចាស់ស្លាប់ពេញព្រៃ
អ្នកខ្លះត្រូវរបួសបាក់បែកអស់ទាំងជើងដៃ ដេកស្តូកបាត់ស្មារតីចាំតែថ្ងៃក្ស័យជីវា ។

ឯប្រពន្ធនិងកូនតូចស្បៀងក៏ហោចទ្រាំមិនបាន ចោលប្តីក្នុងស្មសានយំបោកប្រាណអន្ទះសា
នឹងនៅកំដរប្តីគ្មានចំណីបរិភោគ្គា ហើយខំកាត់ក្តីមេត្តាចោលសង្សារទាំងអាល័យ ។

ពួកជនពនេចរខំត្រដរឆ្លងព្រៃភ្នំ អត់បាយកូនវាយំឈឺរងំងាប់ច្រើនក្រៃ
ដើរដេកស៊ីជិតខ្មោចក្លិនអសោចិស្អុយពេកក្រៃ ខ្លះហើមធំស្ទឹមស្លៃខ្លះបាក់ដៃបែកសិរសា ។

ដើរប្រុងគ្រប់ជំហានឈានតម្រូវដានអ្នកមុន ខុសដានមុនតែស្ទុនអន្តរាយដល់ជីពជន្មា
រយៈផ្លូវដែលវិបត្តិត្រូវប្រយ័ត្នប្រាំទិវា មួយគាវុត[៣]នៃមាគ៌ាត្រូវយាត្រាអស់ប្រាំថ្ងៃ ។

អ្នកខ្លះមានកូនពីរ[៤]កើតកញ្ជ្រឹលទាំងអស់គ្នា ខំវែកកូនលុះហើមស្មាចរយាត្រាកាត់ព្រឹក្សព្រៃ
ស្ត្រីខ្លះប្រសូតកូននាគីឡសាមប្រាំបី ខ្លះរលូតកូនពីផ្ទៃលំបាកក្រៃស្មើរមរណា ។

ខ្លះមកដល់ភូមិសាឯមកើតកូនស្រីស្រស់ប៉ប្រិម ជីតា[៥]អរញញឹមដាក់ឈ្មោះចៅ សាឯមព្រឹក្សា
ខ្លះកើតកូននៅជើងភ្នំភ្លៀងបំព្រាំសែនរងា ខ្លះចោលម្តាយចាស់ជរានាជើងភ្នំគួរស្រណោះ ។

ផ្លូវឆ្ងាយដាច់ស្រយាលយប់ដេកហាលភ្លៀងនិងខ្យល់ រងាញាក់ស្មើរហាល់រកភ្លើងគល់រលត់អស់
មូសសុចច្រើនពន់ពេកឥតបានដេកបន្តិចសោះ សំពត់អាវទទឹកអស់គ្មានស្ងួតសោះសើមវាល់ព្រឹក។

លុះឧទ័យព្រះសុរិយាហើយនាំគ្នាចរចេញខ្មី ដល់ភ្នំត្បែងមានជ័យរមូលផ្ទៃញ័រគគ្រឹក
អស់កម្លាំងឈប់សម្រាកដោយលំបាកយ៉ាងពន្លឹក ឃ្លានបាយក្រហាយទឹកញ័រល្ហិចល្ហឹកដោយហត់នឿយ។

ដើរដេកផ្ទាល់ផែនដីតាមដងព្រៃក្បែរជើងថ្មល់ ជិតពីរខែស្មើរដាច់ខ្យល់ក្រែងមិនដល់ផ្ទះវិញឡើយ
ខោអាវថ្មីគ្មានសល់សោះដូរស៊ីអស់តាមផ្លូវហើយ គ្មានទាំងកន្ទេលខ្នើយដេកកើយដៃអស់សង្ឃឹម ។

មិនអាចទ្រាំក៏នាំគ្នាភៀសអាត្មាប្រថុយស្លាប់ ផ្សងព្រេងស្វែងរកភ័ព្វឆ្ពោះពាយព្យទិសបស្ចិម
ដើរវាងឆ្នាំយាមផ្លូវត្រូវលុយទឹកឆ្ងាយសន្លឹម គេចខ្លួនផុតមានសង្ឃឹមឆ្ពោះបស្ចិមខំយាត្រា ។

ដល់ស្រុកស្រីសោភ័ណស្ទុនដំណើរច្រើនរាត្រី ទម្រាំដល់ជំរំថ្មីភ័យតាមផ្លូវជាច្រើនគ្រា

---

[3] ១-គាវុត គឺរង្វស់បុរាណ មានប្រវែង ២០០០ព្យាម គឺ១០០សិន ។ មួយព្យាម គឺមានចំនួនមួយកាងដៃ គឺប្រវែងបួនហត្ថ ។

[4] តាន់គិមអ៊ានខំវែកកូនពីរ ឈ្មោះនាងផង នាងភាពដែលកើតរោគកញ្ជ្រិលទាំងពីរ។

[5] ជីតាឈ្មោះហ្វអ៊ុំវចាយ ដាក់ឈ្មោះអោយចៅស្រី សាឯមព្រឹក្សា។

ស្នាក់នៅជាងមួយខែព្រួយឥតល្ហែរាល់ទិវា    អាវាសែជនពាលាវារឹបជាន់ឥតប្រណី ។

ពួកបីសាចក្នុងជំរំព្រាំខ្មែរថៃវាបំភ័ន្ត    បំភ័យប្រជាជនមិនឲ្យចូលទៅស្រុកថៃ
ឃាត់ឃាំងប្រជាជនទុកធ្វើឈ្នាន់សម្រាប់កៃ    លក់អំណោយយកកម្រៃធ្វើសេដ្ឋីសម្រាប់វា ។

អន្តរជាតិរដ្ឋបាលថៃប្រោសប្រណីនាំយកឡាន    ទៅដឹកជនភៀសប្រាណរាប់រយឡានចូលភារា
អ្នកខ្លះមិនហ៊ានចេញដោយចាញ់កលល្បិចពួកវា    លុះដល់ខ្មាំងវាយប្រហារទើបនាំគ្នារត់រចល់ ។

ជនភៀសខ្លួនដូចជាចក រសាត់កកក្នុងទន្លេ    គ្មានទីស្ថានស្ថិតស្ថិរតែងតែរេទៅតាមខ្យល់
ផ្សងព្រេងក្នុងជលសាក្រោមបញ្ជានៃកម្មផល    ខ្លះត្រូវស្លាប់ខ្លះនៅសល់ខ្លះឡើងដល់ស្ថានសួគ៌ា ។

គឺស្លាប់ដោយពួកព្រៃចោរចង្រៃជាច្រើនក្រុម    ច្បាំងគ្នាដណ្ដើមធំក្នុងជំរំក្រៅនានា
ទ័ពយួនក៏ចូលវាយកៀរយករាស្ត្របានច្រើនគ្នា    រុញត្រឡប់ទៅកម្ពុជាស្វ័យត្រានវាប្លន់យកអស់។

សម្រាតយកទាំងអាវខោគ្មានអាសូរខ្មែរដូចគ្នា    ផ្ដាច់ផ្ដិលទាំងជីវាស្លាប់ត្រៀបត្រាគ្មានស្រណោះ
ពួកប៉ុលពតក៏វាកៀរដណ្ដើមគ្នាបែកខ្ញែកអស់    ជនកម្ពុជាត្រូវរងគ្រោះមិនចប់សោះព្រោះអាខ្មៅ ។

គ្រោះអាសន្នក្នុងគ្រានោះសូរគ្រាប់ផ្ទុះខ្លាំងអនេក    ជ្រួលច្របល់គ្មានបានដេករែកស្ពាយរត់គ្មានទីដៅ
ស្លាប់របួសច្រើនពេកណាស់ខ្លះស្លាប់កូនសូន្យទាំងចៅ    ទារកខ្លះស្លាប់ម៉ែឪនៅកំព្រាក្នុងស្មសាន ។

អង្គការកាកបាទខំខ្មីឃ្មាតទៅសង្គ្រោះ    ដឹកយកអ្នករបួសមកព្យាបាលជាច្រើនឡាន
ព្រមទាំងកូនកំព្រាអនាថាទាំងប៉ុន្មាន    ចូលជំរំដោយប្រោសប្រាណបានក្សេមក្សាន្តផុតពីទុក្ខ ។

ឧបត្ថម្ភគ្រឿងបរិក្ខានិងអាហារទាំងឆៅឆ្អិន    ដល់ជនឥណ្ឌូចិនដែលភៀសខ្លួនរកក្ដីសុខ
ខ្លាចរបបនៃកុម្មុយនិស្តហើយគេចជៀសរត់ចោលស្រុក    ដើម្បីឲ្យផុតទុក្ខរត់សម្រុកចូលស្រុកថៃ ។

ទោះយួនបាញ់ស្កាត់យ៉ាងណាក៏មិនរារួញថយក្រោយ    គ្រាប់មីនផ្ទុះក៏ដោយរុលមិនថយទាំងប្រុសស្រី
ពុះពារប្ដូរស្លាប់រស់ឆ្ពោះទៅរកលោកទីបី    នឹងកសាងជីវិតថ្មីរកសេរីភាពថ្លៃថ្លា ។

ខំទ្រាំច្រើនខែឆ្នាំស៊ូរងកម្មក្នុងជំរំ    រដ្ឋបាលថៃឃួបឃុំសៀមផាក់ច្រំឥតមេត្តា
ខ្លះត្រូវវាយសម្លាប់ប្លន់យកទ្រព្យរាល់មាសា    ស្ទើរតែរាល់ទិវារំលោភគ្នាទាំងបំពាន ។

ជំរំឡុមភីនីទីអវសាននៃស្រុកថៃ    អាប់អួរខ្លាំងពេកក្រៃដេកផ្ទាល់ដីដូចតិរច្ឆាន
ទឹកជ្រាំជាំកខ្វក់ស្អុយលាមកពេញទីស្ថាន    មូសច្រើនខាំរំខានក្រហាយប្រាណអន្ទះសា ។

លុះបានឡើងយន្តហោះផ្លោះចេញផុតពីដីថៃ
ហើរស្វែងរកសេរីក្នុងភពថ្មីរដ្ឋនានា
បីដូចសត្វបក្សីរួចពីដៃព្រានពាលា
ខ្លះបានដល់ម៉ានីឡាតាមយថាកម្មទ្រទ្រង់ ។

រដ្ឋបាលហ្វីលីពីនឥតបៀតបៀនជនភៀសខ្លួន
ព្រមទាំងជនជាតិគេរាប់អានខ្មែរដោយស្មោះត្រង់
គឺលាវខ្មែរនិងយួនគេថែថ្នូនដោយផ្ចិតផ្ចង់
ក្នុងជំរំមានព្រះសង្ឃលោកទ្រទ្រង់ពុទ្ធសាសនា ។

ខ្លះទៅម៉ាឡេស៊ីអូស្ត្រាលីស្រុកបារាំង
ដឹកយកជនភៀសខ្លួនលាវខ្មែរយួនចូលភារា
សហរដ្ឋអាមេរិកាំងមានកម្លាំងខ្លាំងមហិមា
ច្រើនសែននាក់ដោយគណនាឲ្យនៅជាអចិន្ត្រៃយ៍ ។

យីពុនអ៊ីតាលីស្វីសអូទ្រិសអាឡឺម៉ង់
អង់គ្លេសកាណាដាឥណ្ឌូណេស៊ីប្រទេសថៃ
បែលស៊ិកនូវែលសឺឡង់តៃវ៉ាន់ហុងកុងសឹង្ហបូរី
ជួយស្រង់សត្វពីជលស័យរួចពីភ័យដោយករុណា ។

គុណូបការៈនៃសហប្រជាជាតិ
បានស្រង់សត្វដែលលិចលង់រសាត់ក្នុងមហាជលធារ
អង្គការកាកបាទមានគុណធ្ងន់ដ៏មហិមា
លាវវៀតណាមនិងកម្ពុជាដោយព្រហ្មវិហារធម៌ទាំងបួន ។

សូមសង្ខេបស្លេះសេចក្តីដោយបទខ្លីត្រឹមនេះចុះ
របបព្រៃខ្មែរក្រហមបានចារឹកទុកជាក្បួន
ជនានុជនទាំងស្រីប្រុសចាំទុកចុះកុំភ្លេចខ្លួន
ប្រវត្តិសាស្ត្រផ្តាំតកូនដល់ចៅទួតលួតលា[៦]អើយ ។

យើងខ្ញុំជនភៀសខ្លួនមានចំនួនប្រាំមួយនាក់[៧]
លើកទីពីរតស៊ូទៀតចូលស្រុកសៀមមិនរាងឡើយ
ត្រូវសៀមដេញទម្លាក់ភ្នំដងរែករួចម្តងហើយ
ទម្រាំបានដល់ត្រើយត្រូវអស់ពេលពីរវស្សា ។

នៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយ
ត្រូវបានជិះយន្តហោះផ្លោះចេញផុតពីម៉ានីឡា
ដប់ប្រាំពីរផុតទុក្ខព្រួយនៅកណ្តាលខែកក្កដា
ចូលមកដល់អ៊ុយអេះអាមហាប្រទេសលោកសេរី ។

សូមថ្លែងអំណរគុណដល់លោកប្អូនសុវណ្ណជា
ឲ្យបានមករស់នៅក្នុងប្រទេសលោកទីបី
ដែលបានរ៉ាប់ធានាយកយើងខ្ញុំដោយមេត្រី
បានផុតពីទុក្ខភ័យមានសេរីភាពថ្លៃថ្លា ។

និពន្ធដោយ

វាន់ លី
ទីក្រុងឡូវែល, រដ្ឋម៉ាស្សាឈូសែត, សហរដ្ឋអាមេរិក  គ.ស. ១៩៨២

6 ត្រង់នេះគឺចង់សំដៅលើញាតិទាំងប្រាំពីរសន្តាន គឺ (១)ជីដូនជីតា (២)មាតាបិតា (៣)កូន (៤)ចៅ (៥)ចៅទួត (៦)ចៅលួត  និង(៧) ចៅលា។

7 ក្រុមគ្រួសារទាំងប្រាំមួយនាក់នោះ គឺតាទីវស៊ីមវាន់ ហៅវាន់លី, ហូបានហូ, នាងកែវ, នាងគជ់, លីឈីវប៊ី, និងម៉ាតាន់ស៊ា។